ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

**សភាព្រហ្មទណ្ឌ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១៩៤

ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២

**សាលដីកា**

លេខ ២៧២ "III"

ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២

ដែលមានសមាសភាពនៃអង្គជំនុំជម្រះ ៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-ឯកឧត្តម [redacted] ជាចៅក្រម

៣-លោកជំទា[redacted] ជាចៅក្រម

៤-ឯកឧត្តម [redacted] ជាចៅក្រម

៥-ឯកឧត្តម [redacted] ជាចៅក្រម

៦-លោកជំទាវ [redacted] ជាចៅក្រម

៧-ឯកឧត្តម [redacted] ជាចៅក្រម

៨-ឯកឧត្តម [redacted] ជាចៅក្រម

៩-ឯកឧត្តម [redacted] ជាចៅក្រម

**ចៅក្រមរបាយការណ៍**

ឯកឧត្តម [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ជាអគ្គព្រះរាជអាជ្ញារង

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ១៣៨ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ របស់ឯកឧត្តមព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ និងបណ្តឹងសាទុក្ខលេខ ១៤៣ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោ[redacted] លីម ដែលប្តឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ ២០ "ក្រVI.ស.អ" ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលមាន៖

**-ជនជាប់ចោទ ៖**

-ឈ្មោះ[redacted] **សុវណ្ណនី** ភេទស្រី អាយុ៤០ឆ្នាំ សញ្ជាតិខ្មែរ កន្លែងកំណើតភូ[redacted] ស្រុក[redacted] ខេត្ត[redacted] ទីលំនៅបច្ចុប្បន្ន៖ ផ្ទះលេ[redacted] ភូមិ[redacted] សង្កា[redacted] ខណ្ឌ

មានជ័យ រាជធានីភ្នំពេញ មានប្តីឈ្មោះ[redacted]មានកូន០៣នាក់ ឪពុកឈ្មោះ[redacted](ស) ម្តាយឈ្មោះ [redacted](ស) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន ។

**ជាប់ចោទពីបទ** ប្រើប្រាស់ឯកសារសាធារណៈក្លែង ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៤ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៦៣០ នៃក្រមព្រហ្មទណ្ឌ ។

**ដើមបណ្តឹងរដ្ឋប្បវេណី**

-ឈ្មោ[redacted]លីម ភេទស្រី អាយុ៦៥ឆ្នាំ សញ្ជាតិខ្មែរ លំនៅបច្ចុប្បន្នផ្ទះលេ[redacted]ផ្លូវលេ[redacted] សង្កាត់[redacted] ខណ្ឌ[redacted]រាជធានីភ្នំពេញ ។ **(អ្នកប្តឹងសាទុក្ខ)**

**-លោ[redacted]រ៉ាដា ជាមេធាវីតំណាងដោយអាណត្តិ ។**

## អំពីអង្គហេតុ

កាលពីឆ្នាំ២០០៧ ឈ្មោះ[redacted] សុធារ៉ា បានលក់ដីមួយកន្លែងទំហំ ៧៦ ៣២០ ម៉ែត្រក្រឡា ស្ថិតនៅភូមិ[redacted] ខណ្ឌ[redacted] រាជធានីភ្នំពេញ ទៅឱ្យឈ្មោ[redacted] លីម ក្នុងតម្លៃ[redacted]ដុល្លារអាមេរិក ដោយបាន បង្ហាញលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីពីប្រជាពលរដ្ឋក្នុងភូមិសាស្ត្រខាងលើ ទើបឈ្មោ[redacted]លីម យល់ព្រមទិញដីធ្លីខាងលើពីឈ្មោះ[redacted] សុធារ៉ា និងបានធ្វើលិខិតពលរដ្ឋផ្ទេរសិទ្ធិកាន់កាប់ដីធ្លី នៅចំពោះមុខមេភូមិជើងឯក តែក្រោយពីទិញដីរួច ឈ្មោ[redacted]លីម មិនទាន់បានចូលទៅគ្រប់គ្រងដីនេះនៅឡើយ ។ នៅឆ្នាំ២០១៤ ឈ្មោ[redacted]លីម បានទៅបោះបង្គោលតាមព្រំដីខាងលើ ស្រាប់តែឈ្មោះ[redacted] សុវណ្ណនី បានអះអាងថាដីខាងលើនេះជារបស់ខ្លួនដោយសំអាងទៅលើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីចំនួន៤ច្បាប់ គឺមានលិខិតលេខ ១០១/០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៤ លិខិតលេខ ៤៣៥/០៥ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៤ លិខិតលេខ ៤២៨/០៤ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៤ និងលិខិតគ្មានលេខចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៤ ដោយមានចុះហត្ថលេខាឈ្មោ[redacted]លន ចៅសង្កា[redacted]ជាអ្នកដឹងលឺ ។ តែក្រោយពីសមត្ថកិច្ចធ្វើកោសល្យវិច័យលើលិខិតទាំងបួនខាងលើនេះ ឃើញថា ស្នាមហត្ថលេខាដែលសរសេរឈ្មោ[redacted] លន លើលិខិតទាំងបួនខាងលើនេះមិនដូចគ្នាឡើយ ដូចមានបញ្ជាក់ក្នុងលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីទាំង៤ច្បាប់ខាងលើ ដែលតម្កល់នៅសាលាសង្កាត់ត្រូវបានចៅសង្កា[redacted]ធ្វើរបាយការណ៍បញ្ជាក់ថា រកមិនឃើញឯកសារតម្កល់នៃលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីទាំង៤ ច្បាប់ខាងលើ នៅសាលាសង្កា[redacted]ឡើយ ។

**-បានឃើញ សាលក្រមលេខ ៣៣៣០ “ផ” ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖**

១-ឱ្យឈ្មោ[redacted] សុវណ្ណនី ភេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែរ រួចផុតពីបទចោទប្រកាន់ពីបទ ប្រើប្រាស់ឯកសារសាធារណៈក្លែង ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលអំឡុងឆ្នាំ២០១៤ តាមបញ្ញត្តិមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៨ កំបាំងមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ។

ទុកសិទ្ធិប្ដឹងទាស់និងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

**-បានឃើញ** បណ្ដឹងឧទ្ធរណ៍លេខ ៩៦៦ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោ[redacted]លីម ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៣៣០ "ផ" ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

**-បានឃើញ** បណ្ដឹងឧទ្ធរណ៍លេខ ៩២១ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់លោក[redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៣៣០ "ផ" ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេច ទាំងមូល ។

**-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ២៤ ក្រII "វ" ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖**

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូង រាជធានីភ្នំពេញ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោ[redacted]លីម ទុកត្រឹមត្រូវតាមច្បាប់ចំពោះផលប្រយោជន៍រដ្ឋប្បវេណី និងចំពោះផ្នែកអាជ្ញាមិនអាចទទួលយកបាន ។

៣-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ ៣៣៣០ "ផ" ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលា ដំបូងរាជធានីភ្នំពេញ ជាអសាបង់ ។

៤-ផ្ដន្ទាទោសឈ្មោះ[redacted] **សុវណ្ណនី** ដាក់ពន្ធនាគារកំណត់ ០២ (ពីរ)ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតា ពីបទ **ប្រើប្រាស់ឯកសារសាធារណៈក្លែង** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ ។

៥-បង្គាប់ឲ្យជនជាប់ចោទឈ្មោ[redacted] **សុវណ្ណនី** សងសំណងជម្ងឺចិត្តចំនួន១០ ០០០ ០០០ (ដប់លាន) រៀល ទៅឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោ[redacted]លីម ការទាមទារលើសពីនេះលើកចោល ។

៦-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈថ្ងៃ ទី ០៦ ខែមីនា ឆ្នាំ២០២០ កំបាំងមុខជនជាប់ចោទចំពោះមុខមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ។

-ទុកសិទ្ធិប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។

**-បានឃើញ** បណ្ដឹងទាស់លេខ៣២ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted]**សុវណ្ណនី** ប្ដឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ២៤ ក្រII "វ" ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ របស់ សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១៥៣ ក្រVសស ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលបណ្តឹងទាស់លេខ ៣២ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ របស់ឈ្មោ[redacted]សុវណ្ណនី ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២៤ក្រll "វ" ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការទាំងមូលដដែល ។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោ[redacted] សុវណ្ណនី បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ១០ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណនី ប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌ ១៥៣ ក្រVសស ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

**-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ២១២ "I" ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖**

១-ទទួលបណ្តឹងសាទុក្ខលេខ ១០ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោ[redacted]សុវណ្ណនី។

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ១៥៣ ក្រVសស ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ៣២ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ ។

**-បានឃើញ សាលដីកាលេខ ២០ "ក្រVI.ស.អ" ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖**

១-ទទួលជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៨៧០ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ២១២ (វ) ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ របស់តុលាការកំពូល ។

២-ឲ្យឈ្មោ[redacted]សុវណ្ណនី ភេទស្រី អាយុ៤០ឆ្នាំ រួចផុតពីបទចោទប្រកាន់នូវបទ ប្រើប្រាស់ឯកសារសាធារណៈក្លែង ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៤ តាមបញ្ញត្តិមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-សាលដីកានេះបានជំនុំជម្រះនៅថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី តែចំពោះមុខមេធាវីការពារ

សិទ្ធិឱ្យជនជាប់ចោទ និងមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនា ថ្ងៃចន្ទ ១១ រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ។

ទុកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

**-បានឃើញ** បណ្តឹងសាទុក្ខលេខ ១៣៨ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ **របស់ឯកឧត្តមព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ** ប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌ ២០ "ក្រVI.ស.អ" ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

**-បានឃើញ** បណ្តឹងសាទុក្ខលេខ ១៤៣ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោ[redacted] លីម ប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌ ២០ "ក្រVI.ស.អ" ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

**-បានឃើញ** សារណាការពារ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២ **របស់ឯកឧត្តមព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ** ។

**-បានឃើញ** សារណាតប ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ របស់មេធា[redacted]ជាអ្នកតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]លីម ។

## នាពេលសវនាការនៅតុលាការកំពូល

-ចៅក្រមរបាយការណ៍អានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្តីសន្និដ្ឋាននិងប្តឹងសុំថា ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ និងដើមបណ្តឹងបានប្តឹងសាទុក្ខលើសាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញ។ តាមមាត្រា ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី មានអានុភាពតែលើសំណងរដ្ឋប្បវេណីតែប៉ុណ្ណោះ ។ តាមសារណា ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២០ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញបានប្តឹងសាទុក្ខ ដោយលើកមូលហេតុថា មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទឈ្មោះ[redacted] សុវណ្ណនី មានដូចក្នុងសំអាងហេតុនៅក្នុងសាលដីការបស់សាលាឧទ្ធរណ៍លេខ ២៤ ក្រII (វ) ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ និងលេខ ១៥៣ ក្រVស.ស ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញរួចហើយ ។ ការដែលតុលាការកំពូលបង្វិលសំណុំរឿងមកឱ្យសាលាឧទ្ធរណ៍ជម្រះជាថ្មី ដោយលើកមូលហេតុជាច្រើនចំណុចមកនេះ គឺតុលាការកំពូលចង់ឱ្យសាលាឧទ្ធរណ៍ពិនិត្យ និងស្រាវជ្រាវបន្ថែមឱ្យឃើញកាន់តែច្បាស់ប៉ុណ្ណោះ ។ ប៉ុន្តែបែរជាសាលាឧទ្ធរណ៍ភ្នំពេញ សម្រេចឱ្យជនជាប់ចោទឈ្មោ[redacted] សុវណ្ណនី រួចផុតពីបទចោទ ដោយមិនបានស្រាវជ្រាវអ្វីបន្ថែម តាមការចង្អុលបង្ហាញពីតុលាការកំពូល នោះជាការមិនត្រឹមត្រូវ ។ គួរសាទុក្ខលើកទីII ជូនតុលាការកំពូលពិចារណា និងសម្រេចតាមច្បាប់ ។ ការលើកឡើងរបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពុំមានមូលហេតុណាមួយដូចបានបញ្ញត្តិនៅក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ។ សាលដីកាព្រហ្មទណ្ឌលេខ ២០ ក្រIV ស.ស ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់សាលា

ឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្ដីមកនេះ មានភស្តុតាង និងសំអាងហេតុត្រឹមត្រូវតាមច្បាប់ហើយគប្បីតម្កល់ទុកជាបានការ ។តំណាងមហាអយ្យការសុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការ ។

-មេធា[redacted] វ៉ាដា ជាអ្នកតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើសេចក្ដីសន្និដ្ឋានថា ខ្លួនសូមរក្សាខ្លឹមសារដែលបានដាក់សារណាតប ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ ។ ចំពោះការធ្វើកោសល្យវិច័យ បង្ហាញថា ស្នាមហត្ថលេខាឈ្មោ[redacted]លន លើលិខិតផ្ទេរសិទ្ធិទាំង ៤ ច្បាប់របស់ជនជាប់ចោទ និងស្នាមហត្ថលេខាសរសេរឈ្មោះ[redacted] លន ដែលចុះនៅលើឯកសារដែលមានតម្កល់ទុកនៅសាលាសង្កាត់ គឺមិនដូចគ្នាឡើយ ហើយមិនមានលិខិតស្នាមតម្កល់ទុកនៅសាលាសង្កាត់ទេ ក៏ដូចជាគល់បញ្ជីជាមួយនឹងលិខិតផ្ទេរសិទ្ធិទាំង៤ ច្បាប់នេះ ។ លិខិតទាំងអស់របស់ឈ្មោះ[redacted]សុវណ្ណនី គឺពិតជាឯកសារក្លែងក្លាយ ។

**សំណូមពរ** សូមតុលាការកំពូលមេត្តាសម្រេចផ្ដន្ទាទោសជនជាប់ចោទតាមនីតិវិធីច្បាប់ និងតម្កល់សាលដីកាលេខ ១៥៣ ក្រV សស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការ ។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សារណាការពាររបស់ឯកឧត្ដមអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល និងសេចក្ដីសន្និដ្ឋានរបស់មេធាវីតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

**១.យល់ឃើញថា** បណ្ដឹងសាទុក្ខបណ្ដឹងលេខ ១៣៨ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ **របស់ឯកឧត្ដមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ** និងបណ្ដឹងសាទុក្ខលេខ ១៤៣ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោ[redacted]លីម ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿង នេះមកជំនុំជម្រះ បានតាមមាត្រា ៦២ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤១៧, មាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**២.យល់ឃើញថា** នាពេលសវនាការ តុលាការកំពូលបានទទួលពាក្យស្នើសុំលើកពេលសវនាការ របស់មេធា[redacted] ជាអ្នកការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោ[redacted]សុវណ្ណនី ដោយលើកមូលហេតុថា កូនក្ដីខ្លួនមានធុរៈសំខាន់ក្នុងគ្រួសារ ត្រូវទៅមន្ទីរពេទ្យថៃជាបន្ទាន់នោះ តុលាការកំពូលមិនអនុញ្ញាតឱ្យតាមសុំទេ ពីព្រោះតាមមាត្រា ៤៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលអាចធ្វើសវនាការដោយមិនចាំបាច់ស្ដាប់ចម្លើយរបស់ភាគីនៃសំណុំរឿងព្រហ្មទណ្ឌបាន និងត្រូវពិចារណាសម្រេចលើបញ្ហាច្បាប់ដែលដើមបណ្ដឹងសាទុក្ខបានលើកឡើងនៅក្នុងសារណាការពារ តាមមាត្រា៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះរឿងក្ដីនេះមានបទល្មើសចោទប្រកាន់ គឺជាបទល្មើសមជ្ឈិម និងមានសារណាការពាររបស់បុគ្គលប្ដឹងសាទុក្ខបានដាក់ជូន

តុលាការកំពូលរួចហើយ ព្រមទាំងមានតំណាងមហាអយ្យការ និងមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួម តុលាការកំពូលអាចជំនុំជម្រះបាន។

៣.យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ភ្នំពេញសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] សុវណ្ណនី រួចផុតពីបទចោទប្រកាន់នូវបទប្រើប្រាស់ឯកសារសាធារណៈក្លែង ដែលជាបទល្មើសមានចែង និងឱ្យផ្តន្ទាទោស តាមមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ ដោយសំអាងហេតុថា បើទោះបីឯកសារដែលជនជាប់ចោទបានប្រើប្រាស់ត្រូវបានក្លែងបន្លំយ៉ាងណាក៏ដោយ ក៏ជាគោលការណ៍ ដើម្បីសម្រេចអំពីបទល្មើសប្រើប្រាស់ឯកសារសាធារណៈក្លែងនោះទាល់តែសម្រេចអំពីបទក្លែងបន្លំជាមុនសិននោះ **គឺជាការភ័ន្តច្រឡំ** ពីព្រោះថា បទក្លែងបន្លំឯកសារសាធារណៈដែលមានចែងក្នុងមាត្រា៦២៩ និងបទប្រើប្រាស់ឯកសារសាធារណៈក្លែង គឺជាឈ្មោះបទល្មើសពីរផ្សេងគ្នានៅក្នុងក្រមព្រហ្មទណ្ឌ។ ហេតុដូច្នេះ ករណីនេះ មិនមែនជាលក្ខខណ្ឌដែលតម្រូវឱ្យមានការផ្តន្ទាទោសពីបទក្លែងបន្លំឯកសារសាធារណៈជាមុន ទើបអាចកំណត់ពិរុទ្ធភាពពីបទប្រើប្រាស់ឯកសារសាធារណៈក្លែងនោះទេ។ លើសពីនេះទៀត តាមមាត្រា២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាដំបូងទទួលជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌតាមរយៈ ដីកាបញ្ជូនទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរដែលនៅក្នុងដីកានោះត្រូវបានរៀបរាប់ពីអំពើដែលត្រូវបានចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់ ។ ហេតុដូច្នេះ យុត្តាធិការជំនុំជម្រះ មានសមត្ថកិច្ចត្រឹមតែជំនុំជម្រះពីអំពើនិងឈ្មោះបទល្មើសដែលត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរប៉ុណ្ណោះ។ ម្យ៉ាងទៀត បើទោះបីជានៅក្នុងអង្គហេតុព្រហ្មទណ្ឌមួយអាចមានបទល្មើសច្រើនជាងមួយក៏ដោយ តែការកំណត់ឈ្មោះបទល្មើសក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរទៅជំនុំជម្រះ គឺជាឆន្ទានុសិទ្ធិ និងជាសមត្ថកិច្ចផ្តាច់មុខរបស់ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរ។ រីឯ យុត្តាធិការជំនុំជម្រះវិញមានសមត្ថកិច្ចត្រឹមតែពិនិត្យអំពីអត្ថិភាព ឬនត្ថិភាពនៃធាតុផ្សំបទល្មើសគ្រប់គ្រាន់ដោយផ្អែកលើភស្តុតាងក្នុងការកំណត់ពីពិរុទ្ធភាពលើជនជាប់ចោទ ចំពោះបទល្មើសដែលបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរនោះប៉ុណ្ណោះ។

**៤.យល់ឃើញថា** នៅក្នុងអង្គហេតុដែលត្រូវបានប្តឹងចោទប្រកាន់នេះ តុលាការកំពូលពិនិត្យឃើញថាឯកសារចំនួន៤ច្បាប់របស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណនី បានយកមកប្រើប្រាស់ដើម្បីធ្វើជាភស្តុតាង នៃសិទ្ធិនោះ គឺមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ១០១/០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៤ លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ៤៣៥/០៥ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៤ លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ៤២៨/០៤ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៤ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីគ្មានលេខចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៤ ដោយមានចុះហត្ថលេខារបស់ឈ្មោះ [redacted] ចៅសង្កាត់ [redacted]

តាមលទ្ធផលកោសល្យវិច័យលេខ ០១១/១៥ ប្រក/បវ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥ របស់នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ នៃក្រសួងមហាផ្ទៃ បានបញ្ជាក់ថា ស្នាមហត្ថលេខាសរសេរឈ្មោះ [redacted] ដែលចុះនៅលើឯកសារមានសញ្ញាសំគាល់ E1 ដល់ E4

និងស្នាមហត្ថលេខាសរសេរឈ្មោះ[redacted] លន ដែលចុះនៅលើឯកសារមានសញ្ញាសំគាល់ M1, M2 និង M3 គឺ **មិនដូចគ្នាឡើយ** ។ ជាយថាហេតុ តាមលិខិតបញ្ជូនរឿងទៅព្រះរាជអាជ្ញាលេខ១៦១ របក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០១៥ របស់ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាល បានសន្និដ្ឋានថា៖ តាមលទ្ធផលកោសល្យវិច័យរបស់នាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ ឈ្មោះ[redacted] **សុវណ្ណនី** ពិតជាបាន ក្លែងលិខិតសាធារណៈ និងប្រើប្រាស់លិខិតសាធារណៈក្លែងពិតប្រាកដមែន។

**៥.យល់ឃើញថា** ការដែលឈ្មោះ[redacted] **លន** បានឆ្លើយទទួលស្គាល់ហត្ថលេខារបស់ខ្លួននៅលើលិខិតទិញលក់ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ដីដែលជនជាប់ចោទយកមកប្រើប្រាស់នោះ គឺគ្រាន់តែជាការដោះសារប៉ុណ្ណោះ ពីព្រោះ ឈ្មោះ[redacted] **លន** និងជនជាប់ចោទឈ្មោះ[redacted] **សុវណ្ណនី** គឺជាបុគ្គលមានទំនាក់ទំនងញាតិជិតស្និតក្នុងឋានៈជាឪពុក និងកូនបង្កើត។ ហេតុដូច្នេះ ចម្លើយរបស់ឈ្មោះ[redacted] លន មិនអាចជឿ និងយកជាការបានឡើយ។ ចំណែកឯ ឯកសារផ្ទេរសិទ្ធិទាំង ៤ច្បាប់នោះទៀតសោត ពុំត្រូវបានរកឃើញតម្កល់ទុក ឬមានចុះលេខក្នុងសៀវភៅតល់បញ្ជីរបស់សាលាសង្កាត់ឡើយ។ លើសពីនេះទៀត ក្នុងកំណត់ហេតុស្តាប់ចម្លើយចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ជនជាប់ចោទបានឆ្លើយថា “ពេលនាងខ្ញុំទិញដីទាំង៤កន្លែងខាងលើនេះ នាងខ្ញុំបានផ្តិតមេដៃចំពោះមុខចៅសង្កាត់[redacted] ប៉ុន្តែខ្លួនមិនឃើញម្ចាស់ដីផ្តិតមេដៃនៅចំពោះមុខខ្លួនទេ។ ហើយចំនួន១សន្លឹកទៀត ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៤ គឺខ្លួនផ្តិតមេដៃចំពោះមុខភូមិចំរើនផល តែមិនបានឃើញអ្នកលក់ដីផ្តិតមេដៃទេ” ហើយភស្តុតាង នេះមានលក្ខណៈស៊ីសង្វាក់ទៅនឹងរបាយការណ៍ស្តីពីការចុះអង្កេតស្រាវជ្រាវលើឯកសារផ្ទេរសិទ្ធិកាន់កាប់ដីនៅក្នុងសង្កាត់[redacted]របស់ចៅសង្កាត់[redacted]តាមលិខិតលេខ០៣១/១៤ រ.ប.ក ចុះ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ជាពិសេសត្រង់ចំណុចឯកសារដើមដែលមានតម្កល់នៅសាលាសង្កាត់ត្រឹមត្រូវដែលមានកាលបរិច្ឆេទដូចគ្នានឹងលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីរបស់ជនជាប់ចោទ គឺ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៤ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៤ និង ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៤ មានតែឈ្មោះ អ្នកផ្ទេរសិទ្ធិ និងអ្នកទទួលសិទ្ធិផ្សេង ហើយមិនមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីរបស់ឈ្មោះ[redacted]សុវណ្ណនី ដែលបានយកមកប្រើប្រាស់នោះទេ ដែលការណ៍នេះបញ្ជាក់ឲ្យឃើញលើសពីវិមតិសង្ស័យថា ជនជាប់ចោទពិតជាបានដឹងថា ឯកសាររបស់ខ្លួនទាំង៤ច្បាប់នេះ គឺជាឯកសារដែលត្រូវបានធ្វើឡើងដោយមិនត្រឹមត្រូវ ឬមិនពិត(ឯកសារក្លែង) ហើយនៅតែបន្តប្រើប្រាស់ក្នុងការធ្វើជាភស្តុតាងបញ្ជាក់សិទ្ធិ ដែលធ្វើឲ្យប៉ះពាល់ដល់ ដីរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានឯកសារត្រឹមត្រូវចំនួន ៦ ច្បាប់(តាមការបញ្ជាក់របស់ចៅសង្កាត់ជើងឯកឈ្មោះ[redacted]ស៊ីវ តាមលិខិតលេខ ២០០២/១៤ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៤ និងតាមលិខិតលេខ៥៥៤/២១ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១) គឺ៖

-លិខិតផ្ទេរសិទ្ធិកាន់កាប់ដី ឈ្មោះ[redacted] ថា មកឲ្យឈ្មោះ[redacted] **សុធារ៉ា** លេខ ០៨៥/០៦ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៦ ចុះហត្ថលេខាដោយចៅសង្កាត់ជើងឯកឈ្មោះ[redacted] **ស៊ីវ** ។

-លិខិតផ្ទេរសិទ្ធិកាន់កាប់ដី ឈ្មោះ[redacted] ស្រីលក្ខ មកឲ្យឈ្មោះ[redacted] **សុធារ៉ា** លេខ ០៨៦/០៦ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០០៦ ចុះហត្ថលេខាដោយចៅសង្កាត់ជើងឯកឈ្មោះ[redacted] **ស៊ីវ** ។

-លិខិតផ្ទេរសិទ្ធិកាន់កាប់ដី ឈ្មោះ[redacted] **យ៉េន** មកឲ្យឈ្មោះ[redacted] **សុធារ៉ា** លេខ ០៨៧/០៦ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០០៦ ចុះហត្ថលេខាដោយចៅសង្កាត់ ជើងឯកឈ្មោះ[redacted] **ស៊ីវ** ។

-លិខិតផ្ទេរសិទ្ធិកាន់កាប់ដី ឈ្មោះ **ស្វាយ លីន** មកឱ្យឈ្មោ[redacted] **សុធារ៉ា** លេខ ០៨៨/០៦ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៦ ចុះហត្ថលេខាដោយចៅសង្កាត់ជើងឯកឈ្មោ[redacted] **ស៊ីវ** ។

-លិខិតផ្ទេរសិទ្ធិកាន់កាប់ដី ឈ្មោ[redacted]សម្បត្តិ មកឱ្យឈ្មោ[redacted]សុធារ៉ា លេខ ០៨៩/០៦ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០០៦ ចុះហត្ថលេខាដោយចៅសង្កាត់ ជើងឯកឈ្មោ[redacted] **ស៊ីវ** ។

-លិខិតផ្ទេរសិទ្ធិកាន់កាប់ដី ឈ្មោ[redacted]រ៉ាត មកឱ្យឈ្មោ[redacted] **សុធារ៉ា** លេខ ០៩០/០៦ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៦ ចុះហត្ថលេខាដោយចៅសង្កាត់ ជើងឯកឈ្មោ[redacted] **ស៊ីវ** ។

បន្ទាប់មកឈ្មោ[redacted] **សុធារ៉ា** រួចហើយ បន្ទាប់មកឈ្មោ[redacted] **សុធារ៉ា** បានធ្វើការលក់ដីនេះ បន្តឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]**លីម** តាមរយៈលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដោយចុះហត្ថលេខាទទួលស្គាល់ពីមេភូមិជើងឯក។

ផ្អែកតាមអង្គហេតុ និងភស្តុតាងដែលបានរកឃើញនេះ អាចសន្និដ្ឋានថា លិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ១០១/០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៤ លិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៤៣៥/០៥ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ ២០០៤ លិខិត ផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៤២៨/០៤ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៤ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ដីគ្មានលេខចុះ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៤ ដោយមានចុះហត្ថលេខារបស់ឈ្មោ[redacted]លន ចៅសង្កាត់ [redacted]គឺជាឯកសារក្លែង។ ហេតុដូច្នេះ អំពើរបស់ឈ្មោ[redacted] **សុវណ្ណនី** ដែលប្រើប្រាស់ឯកសារក្លែងក្នុងការធ្វើជាភស្តុតាងបញ្ជាក់សិទ្ធិនេះ មានធាតុផ្សំបទល្មើសគ្រប់គ្រាន់ក្នុងការកំណត់ពីពិរុទ្ធភាពរបស់ជនជាប់ចោទរូបនេះ ពីបទប្រើប្រាស់លិខិតសាធារណៈក្លែងដែលជាបទល្មើសមានចែងនិងឱ្យផ្តន្ទាទោសតាមមាត្រា៦៣០ នៃក្រមព្រហ្មទណ្ឌ។

**៦.យល់ឃើញថា** ការដែលតំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខ អក្សរចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ ថា សាលដីកាព្រហ្មទណ្ឌលេខ ២០ “ក្រVI.ស.អ” ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលបានសម្រេចឱ្យជនជាប់ចោទរួចខ្លួន មានភស្តុតាង និងសំអាងហេតុ ត្រឹមត្រូវតាមច្បាប់ ហើយគប្បីតម្កល់ទុកជាបានការនោះ គឺជាមិនត្រឹមត្រូវទេ ដូចមានសំអាងហេតុខាងលើ។ ផ្ទុយទៅវិញ តាមសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០២១ របស់តំណាងមហាអយ្យការអមតុលាការកំពូលដែល បានសន្និដ្ឋានថា សាលដីកាព្រហ្មទណ្ឌលេខ ២៤ក្រ៉ៃ “វ” ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ របស់សាលា ឧទ្ធរណ៍ភ្នំពេញដែលបានរកឃើញពិរុទ្ធភាពរបស់ជនជាប់ចោទ និងបានសម្រេចផ្តន្ទាទោសជនជាប់ចោទនោះថា មានភស្តុតាង និងសំអាងហេតុត្រឹមត្រូវ តាមច្បាប់ ហើយគប្បីតម្កល់ទុកជាបានការដែរ។ ទោះបីជាតំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានបែបនេះក្តី តុលាការកំពូលបានពិចារណាអំពីអង្គហេតុចោទប្រកាន់ និងបានធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនដូចសំអាងហេតុខាងលើនេះ។

**៧.យល់ឃើញថា** បណ្តឹងសាទុក្ខបណ្តឹងរបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ និងបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]លីម មានមូលហេតុនៃបណ្តឹងសាទុក្ខត្រឹមត្រូវ តាមមាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៨.**យល់ឃើញថា** សាលដីកាព្រហ្មទណ្ឌលេខ ២០ "ក្រVI.ស.អ" ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលបានសម្រេចសេចក្ដីមកនេះខុសច្បាប់ ។

៩.**យល់ឃើញថា** បើទោះបីជាសាលដីកាព្រហ្មទណ្ឌលេខ ១៥៣ ក្រVសស ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២៤ក្រII "វ" ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការដែលបានសម្រេចផ្ដន្ទាទោសឈ្មោ[redacted]សុវណ្ណនី ដាក់ ពន្ធនាគារកំណត់ ០២ (ពីរ)ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតា ពីបទប្រើប្រាស់ឯកសារសាធារណៈក្លែង ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្ដន្ទាទោស តាមបញ្ញត្តិ មាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ និងបង្គាប់ឱ្យជនជាប់ចោទឈ្មោ[redacted]សុវណ្ណនី សងសំណងជម្ងឺចិត្តចំនួន ១០,០០០.០០០ (ដប់លាន) រៀល ទៅឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោ[redacted]លឹម នោះ **ឃើញថា** មិនខុសច្បាប់ទេ ប៉ុន្តែមានលក្ខណៈស្រាលបំផុតក៏ដោយ ក៏តុលាការកំពូលមិនអាចកែប្រែដំឡើងទណ្ឌកម្មលើជនជាប់ចោទរូបនេះបានឡើយ ពីព្រោះ មានតែជនជាប់ចោទប៉ុណ្ណោះដែលបានប្ដឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១៥៣ ក្រVសស ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញនេះ ហើយមិនមានបណ្ដឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញានោះទេ។ ហេតុដូច្នេះ តុលាការកំពូលគប្បីសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១៥៣ ក្រVសស ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញនេះ ទុកជាបានការដដែល ដោយពុំចាំបាច់សរសេរជាថ្មីឡើងវិញដដែលនោះទេ។

១០.**យល់ឃើញថា** ត្រង់ចំណុចទី២ នៃផ្នែកសេចក្ដីសម្រេចបញ្ចប់នៃសាលដីកាព្រហ្មទណ្ឌលេខ ១៥៣ ក្រVសស ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ មានការសរសេរខុសអក្ខរាវិរុទ្ធដែលជាកំហុសខាងសម្ភារៈ គឺ "**ខែធ្នូ ឆ្នាំ២០១៩**" ដែលតាមត្រឹមត្រូវ គឺ"**ខែមីនា ឆ្នាំ២០២០**"។ ហេតុដូច្នេះ តុលាការកំពូលគប្បីកែតម្រូវចំណុចនេះ។ ជាបច្ច័យនេះ ចំណុច២នៃផ្នែកសេចក្ដីសម្រេចបញ្ចប់នៃសាលដីកាលេខ១៥៣ ក្រVសស ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលត្រឹមត្រូវ គឺ"តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២៤ក្រII "វ" ចុះថ្ងៃទី០៦ **ខែមីនា ឆ្នាំ២០២០** របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការទាំងមូលដដែល"។

## ហេតុដូច្នេះសម្រេច៖

**១.ទទួល**បណ្ដឹងសាទុក្ខបណ្ដឹងលេខ១៣៨ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ របស់**ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ** និងបណ្ដឹងសាទុក្ខលេខ១៤៣ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោ[redacted]លឹម ។

**២.បដិសេធ**សាលដីកាព្រហ្មទណ្ឌលេខ២០ "ក្រVI.ស.អ" ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញទាំងមូល។

**៣.តម្កល់**សាលដីកាព្រហ្មទណ្ឌលេខ១៥៣ ក្រVសស ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការ ដោយកែតម្រូវត្រង់ចំណុចទី២ ពី"**ខែធ្នូ ឆ្នាំ២០១៩**" ទៅជា"**ខែមីនា ឆ្នាំ២០២០**"។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ ។

| | |
|---|---|
| -ឯកឧត្តម [redacted] | ជាប្រធាន |
| -ឯកឧត្តម [redacted] | ជាចៅក្រម |
| -លោកជំទាវ [redacted] | ជាចៅក្រម |
| -ឯកឧត្តម [redacted] | ជាចៅក្រម |
| -ឯកឧត្តម [redacted] | ជាចៅក្រម |
| -លោកជំទាវ [redacted] | ជាចៅក្រម |
| -ឯកឧត្តម [redacted] | ជាចៅក្រម |
| -ឯកឧត្តម [redacted] | ជាចៅក្រម |
| -ឯកឧត្តម [redacted] | ជាចៅក្រម |
| -លោកស្រី [redacted] | ជាក្រឡាបញ្ជី |

---

**បានចម្លងត្រឹមត្រូវតាមសាលដីកាដើមៗ**

ថ្ងៃអង្គារ ១៤រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

ថ្ងៃអង្គារ ១៤រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

---

"យើង[redacted]ក្រឡាបញ្ជីតុលាការកំពូល បញ្ជាក់ថា សាលដីកានេះបានចូលជាស្ថាពរ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ និងមានអានុភាពអនុវត្ត តាមច្បាប់ ។"

**"សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាទ្រង់ត្រាស់បង្គាប់មកអ្នក អនុវត្តសាលដីកាឱ្យសម្រេចតាមសាលដីកានេះ និងឱ្យអាជ្ញាធរគ្រប់តំណែងគ្រប់ថ្នាក់ ជួយអនុវត្តសាលដីកានេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ៗ"**

ថ្ងៃអង្គារ ៧ កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]